# វិធាននីតិវិធីបណ្ដឹងឧទ្ធរណ៍សម្រាប់ការផ្លាស់ប្ដូរអត្ថប្រយោជន៍សុខភាពវ៉ាស៊ីនតោន


1. គោលបំណង
2. និយមន័យ
3. តើសេចក្ដីសម្រេចអ្វីដែលអាចដាក់បណ្ដឹងឧទ្ធរណ៍
4. ការស្នើសុំដាក់បណ្ដឹងឧទ្ធរណ៍
5. ការបដិសេធបណ្ដឹងឧទ្ធរណ៍
6. ការប្ដឹងឧទ្ធរណ៍ឆាប់រហ័ស
7. ដំណោះស្រាយក្រៅផ្លូវការ
8. សវនាការមុនពេលកាត់ក្ដី
9. សេចក្ដីជូនដំណឹងអំពីសវនាការ
10. សវនាការ
11. បទដ្ឋាននៃការពិនិត្យឡើងវិញ
12. សាលក្រម
13. បណ្ដឹងឧទ្ធរណ៍នៃសេចក្ដីសម្រេចផ្លាស់ប្ដូរទៅ **HHS**
14. ការផ្លាស់ប្ដូរកាលបរិច្ឆេទនៃសវនាការមុនពេលកាត់ក្ដី ឬ សវនាការ
15. ការតែងតាំងអ្នកតំណាងជំនួសភាគីប្ដឹងឧទ្ធរណ៍
16. អ្នកបកប្រែ
17. ការដកសំណើសុំសវនាការ
18. ការដាក់ឯកសារទៅផ្នែកផ្លាស់ប្ដូរ


## 1. គោលបំណង

វិធាននីតិវិធីទាំងនេះ កំណត់ដំណើរការសម្រាប់ការប្ដឹងឧទ្ធរណ៍ នៃការកំណត់សិទ្ធិទទួលបានដែលត្រូវបានចេញដោយការផ្លាស់ប្ដូរអត្ថប្រយោជន៍សុខភាពវ៉ាស៊ីនតោន (WAHBE, ឬ ផ្នែកផ្លាស់ប្ដូរ)។ វិធានទាំងនេះអនុវត្តតាមច្បាប់សហព័ន្ធ មាត្រា 45 CFR អនុមាត្រា F ដែលគ្រប់គ្រងបណ្ដឹងឧទ្ធរណ៍នៃការកំណត់ការផ្លាស់ប្ដូរ។ មិនមានផ្នែកណាក្នុងវិធានទាំងនេះ មានចេតនាកំណត់ ឬផ្លាស់ប្ដូរតម្រូវការ ឬសិទ្ធិក្នុងលក្ខន្តិកៈ ឬវិធានផ្សេងទៀត។ ប្រសិនបើមានទំនាស់រវាងវិធានទាំងនេះ និងច្បាប់សហព័ន្ធទៅ មាត្រា 45 CFR ផ្នែក 155, អនុមាត្រា F, នោះច្បាប់សហព័ន្ធមានអធិកភាព។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155, អនុមាត្រា F

## 2. និយមន័យ

ចំពោះគោលបំណងនៃវិធាននីតិវិធីទាំងនេះ, គោលការណ៍ខាងក្រោម មានអត្ថន័យដូចតទៅ:

(1) "កំណត់ហេតុបណ្តឹង" មានន័យថា សាលក្រម, រាល់ឯកសារ, សំណើដែលបានដាក់ស្នើក្នុងកិច្ចនីតិវិធី, និង, ប្រសិនបើមានការបើកសវនាការ, កំណត់ហេតុនៃសេក្តីកម្មសវនាការ ឬរបាយការណ៍ផ្លូវការ ដែលមានខ្លឹមសារនៃអ្វីដែលបានកើតឡើងនៅសវនាការ, និងរាល់ការបង្ហាញ ដែលមាននៅសវនាការ។

(2) "ភាគីបណ្តឹងឧទ្ធរណ៍" មានន័យថា អ្នកដាក់ពាក្យបណ្តឹង, អ្នកចុះឈ្មោះ, និយោជក, ឬនិយោជិក ដែលបានដាក់សំណើបណ្តឹងឧទ្ធរណ៍ដែលមានសុពលភាព។

(3) "ជំនុំជំរះសារជាថ្មី" មានន័យថា ការពិនិត្យឡើងវិញនៃបណ្តឹងឧទ្ធរណ៍ដែលត្រូវបានធ្វើឡើងដោយមិនមានសេចក្តីគោរពចំពោះសេចក្តីសម្រេចជាមុនក្នុងករណីនេះ។

(4) "ការផ្លាស់ប្តូរ" មានន័យថា ការផ្លាស់ប្តូរអត្ថប្រយោជន៍សុខភាពវ៉ាស៊ីនតោនដែលបានបង្កើតឡើងក្រោមជំពូក 43.71 RCW.

(5) "មូលហេតុត្រឹមត្រូវ" មានន័យថា មានហេតុផលគ្រប់គ្រាន់ ឬយុត្តិកម្មផ្លូវច្បាប់ចំពោះការខកខានមិនបានបង្ហាញ, ប្តឹង, ឬ ឆ្លើយតបនឹងបណ្តឹង, មូលហេតុផលចំពោះអ្វីដែលមនុស្សម្នាក់បាន ឬ មិនបានធ្វើ, រាប់បញ្ចូលទាំងតែមិនកំណត់ចំពោះបញ្ហាជំងឺ, កាលៈទេសៈផ្សេងទៀត ហួសពីការគ្រប់គ្រងរបស់ខ្លួន, ឬខកខានមិនបានឆ្លើយតបពីព្រោះការជូនដំណឹង ត្រូវបានសរសេរជាភាសាដែលខ្លួនមិនយល់។

(6) "មន្ត្រីអធិបតី" មានន័យថា បុគ្គលដែលមិនលំអៀង ដែលមិនពាក់ព័ន្ធអំពីសេចក្តីសម្រេចដើម ហើយជាអ្នកដែលត្រូវបានតែងតាំងដោយផ្នែកផ្លាស់ប្តូរដើម្បីធ្វើនីតិវិធីបណ្តឹង ក្រោមវិធាននីតិវិធីទាំងនេះ។

(7) "ចាត់ទុកជាមោឃៈ" មានន័យថា ព្យួរទុកបណ្តឹងលើកមុន។

(8) "សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរ" ឬ "ដោយការសរសេរ" មានន័យថា ត្រូវបានផ្ញើតាមប្រៃសណីយ៍, សំណៅចម្លង, ឬ អ៊ីមែល។

3. តើសេចក្តីសម្រេចអ្វីដែលអាចដាក់បណ្តឹងឧទ្ធរណ៍

(1) ការប្តឹងឧទ្ធរណ៍បុគ្គល: អ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ឬ អ្នកចុះឈ្មោះអាចប្តឹងឧទ្ធរណ៍:

(ក) ការសម្រេចសិទ្ធិទទួលបានលើការដាក់ពាក្យស្នើសុំដំបូងសម្រាប់ការចុះឈ្មោះក្នុងគម្រោងសុខភាពដែលមានលក្ខណៈគ្រប់គ្រាន់, រួមបញ្ចូលទាំងការបង់ប្រាក់ជាមុននៃចំនួនទឹកប្រាក់ឥណទានពន្ធបុព្វលាភ និងចំនួននៃការកាត់បន្ថយការចំណាយរួម។

(ខ) ការកំណត់ឡើងវិញនូវសិទ្ធិទទួលបានសម្រាប់អ្នកចុះឈ្មោះក្នុងគម្រោងសុខភាពដែលមានលក្ខណៈគ្រប់គ្រាន់ រួមបញ្ចូលទាំងការបង់ប្រាក់ជាមុននៃចំនួនទឹកប្រាក់ឥណទានពន្ធបុព្វលាភ និងចំនួននៃការកាត់បន្ថយការចំណាយរួម។

(គ) ការសម្រេចសិទ្ធិទទួលបានលើការដាក់ពាក្យស្នើសុំក្នុងអំឡុងពេលការចុះឈ្មោះពិសេស, រួមបញ្ចូលទាំងការបង់ប្រាក់ជាមុននៃចំនួនទឹកប្រាក់ឥណទានពន្ធបុព្វលាភ និងចំនួននៃការកាត់បន្ថយការចំណាយរួម។

(ឃ) ផ្នែកផ្លាស់ប្តូរខកខានមិនបានផ្តល់ការជូនដំណឹងអំពីការសម្រេចសិទ្ធិទទួលបាន (ការកំណត់ ឬ ការកំណត់ឡើងវិញ)។

(ង) ការកំណត់ សិទ្ធិទទួលបានសម្រាប់ការលើកលែងចំពោះអាណត្តិបុគ្គលដែលតម្រូវឲ្យមានការធានារ៉ាប់រង ប្រសិនបើអាចអនុវត្តបាន អនុលោមតាម 45 CFR §155.605

(2) បណ្តឹងឧទ្ធរណ៍របស់និយោជក: និយោជកអាចប្តឹងដោយការកំណត់មួយដែល:

(ក) និយោជកមិនផ្តល់ការធានារ៉ាប់រងសុខភាពដែលផ្តល់ការគ្របដណ្តប់ចាំបាច់អប្បបរមា និងឆ្លើយតបតាមស្តង់ដារតម្លៃ; ឬ

(ខ) ការគ្របដណ្តប់ចាំបាច់អប្បបរមា, គម្រោងតម្លៃអប្បរមាដែលនិយោជកផ្តល់ជូន គឺមិនមែនជាតម្លៃសមរម្យសម្រាប់បុគ្គលិក។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155.505; មាត្រា 45 CFR ផ្នែក 155.555; មាត្រា 45 CFR ផ្នែក 155.605

**4.** ការស្នើសុំដាក់បណ្តឹងឧទ្ធរណ៍

(1) បណ្តឹងឧទ្ធរណ៍ ត្រូវតែបានដាក់ស្នើសុំក្នុងរយៈពេល 90 ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹងអំពីការកំណត់សិទ្ធិទទួលបាន។

(2) បណ្តឹងឧទ្ធរណ៍អាចត្រូវបានស្នើសុំតាមវិធីដូចខាងក្រោម :

(ក) សំបុត្រ, ដោយការផ្ញើទម្រង់បែបបទបណ្តឹងឧទ្ធរណ៍ ដែលរួមមានការជូនដំណឹងពីផ្នែកផ្លាស់ប្តូរអំពីសិទ្ធិទទួលបាន ទៅកាន់អាសយដ្ឋានដែលមាននៅលើទម្រង់បែបបទបណ្តឹងឧទ្ធរណ៍។

(ខ) អ៊ីមែល, ដោយការផ្ញើអ៊ីមែលជាមួយនឹងការស្នើសុំបណ្តឹងឧទ្ធរណ៍ទៅកាន់ appeals@wahbexchange.org. ការស្នើសុំតាមអ៊ីមែល ត្រូវមានឈ្មោះ, អាសយដ្ឋាន, និងលេខទូរស័ព្ទរបស់អ្នកចង់ដាក់បណ្តឹងឧទ្ធរណ៍, កាលបរិច្ឆេទនៃការកំណត់សិទ្ធិទទួលបានដែលត្រូវប្តឹង និងមូលហេតុនៃការប្តឹង។

(គ) ទូរស័ព្ទ, ដោយទំនាក់ទំនងទៅកាន់ផ្នែកផ្លាស់ប្តូរតាមរយៈលេខ 1-855-859-2512 (ដោយឥតគិតថ្លៃ)។

(ឃ) ទូរសារ, ដោយការផ្ញើសំណើបណ្ដឹងឧទ្ធរណ៍តាមរយៈទូរសារលេខ 360-841-7653។

(ង) ប្រព័ន្ធអ៊ីនធឺណេត, ដោយការបំពេញទម្រង់បែបបទបណ្ដឹងឧទ្ធរណ៍អនឡាយលើគេហទំព័រ www.wahbexchange.org ។

(ច) ការដាក់ជូនដោយផ្ទាល់ដៃ ឬ បញ្ជូនតាមសេវាដឹកជញ្ជូនពាណិជ្ជកម្ម, ទៅកាន់ផ្នែកផ្លាស់ប្ដូរ, 810 Jefferson Street SE, Olympia, Washington 98501.

(3) ផ្នែកផ្លាស់ប្ដូរ ត្រូវតែ:

(ក) តាមការស្នើសុំ, ជួយដល់អ្នកដាក់ពាក្យ ឬ អ្នកចុះឈ្មោះ ក្នុងការដាក់សំណើបណ្ដឹងឧទ្ធរណ៍;

(ខ) មិនកំណត់ ឬ ជ្រៀតជ្រែកជាមួយសិទ្ធិរបស់អ្នកដាក់ពាក្យ ឬ អ្នកចុះឈ្មោះក្នុងការដាក់ បណ្ដឹងឧទ្ធរណ៍; និង

(គ) ពិនិត្យមើលសំណើបណ្ដឹងឧទ្ធរណ៍ដែលមានសុពលភាព ដែលបញ្ជូនយ៉ាងត្រឹមត្រូវទៅកាន់ក្រសួងសេវាសុខាភិបាល និងសង្គមនៃរដ្ឋវ៉ាស៊ីនតោន, អាជ្ញាធរថែទាំសុខភាពនៃរដ្ឋវ៉ាស៊ីនតោន, ឬការិយាល័យរដ្ឋវ៉ាស៊ីនតោននៃសវនាការរដ្ឋបាល ។

(4) នៅពេលផ្នែកផ្លាស់ប្ដូរទទួលបានសំណើបណ្ដឹងឧទ្ធរណ៍, ផ្នែកផ្លាស់ប្ដូរនឹងផ្ញើទៅកាន់អ្នកស្នើសុំបណ្ដឹងឧទ្ធរណ៍:

(ក) ការជូនដំណឹងថា បានទទួលបណ្ដឹងឧទ្ធរណ៍;

(ខ) កាលបរិច្ឆេទនៃដំណើរការបណ្ដឹងឧទ្ធរណ៍ រួមទាំងការជូនដំណឹងអំពីថ្ងៃខែ និងពេលវេលានៃសវនាការមុនពេលកាត់ក្ដី, ប្រសិនបើចាំបាច់ត្រូវមានសវនាការ;

(គ) ព័ត៌មានអំពីសិទ្ធិទទួលបានសម្រាប់ការបង់ប្រាក់ជាមុននៃឥណទានពន្ធបុព្វលាភ និងការកាត់បន្ថយការចំណាយរួម អំឡុងពេលបណ្ដឹងឧទ្ធរណ៍;

(ឃ) ការពន្យល់អំពីរាល់ការបង់ប្រាក់ជាមុននៃឥណទានពន្ធបុព្វលាភ ជំនួសឲ្យភាគីបណ្ដឹងឧទ្ធរណ៍ គឺអាចផ្សះផ្សាយដោយសេវាកម្មចំណូលផ្ទៃក្នុងលើរបាយការណ៍ចំណូលសម្រាប់បង់ពន្ធរបស់ភាគីបណ្ដឹងឧទ្ធរណ៍។

(ង) ព័ត៌មានអំពីការស្នើសុំសេវាជំនួយសម្រាប់ភាពងាយស្រួល/អ្នកបកប្រែ អនុលោមតាមច្បាប់សហព័ន្ធដូចមានចែងក្នុងវិធាននីតិវិធី មាត្រា 16។

(5) ភាគីបណ្ដឹងឧទ្ធរណ៍ ត្រូវមានឱកាសក្នុងការពិនិត្យកំណត់ហេតុបណ្ដឹង រួមទាំងរាល់ឯកសារទាំងអស់ដែលនឹងត្រូវប្រើប្រាស់ដោយផ្នែកកផ្លាស់ប្ដូរនៅសវនាការ, នៅរយៈពេលសមរម្យមួយមុនពេលសវនាការ, និងនៅពេលសវនាការ។

(6) នៅពេលផ្នែកកផ្លាស់ប្តូរទទួលបានសំណើបណ្តឹងឧទ្ធរណ៍ដែលមិនមានសុពលភាព ពីព្រោះវាមិនបានឆ្លើយតបទឹងលក្ខខណ្ឌនៃផ្នែកនេះ, ផ្នែកកផ្លាស់ប្តូរត្រូវ:

(ក) ផ្ញើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកដាក់ពាក្យ ឬ អ្នកចុះឈ្មោះ ដែលសំណើបណ្តឹងឧទ្ធរណ៍ត្រូវបានទទួល; និង

(ខ) ពិនិត្យមើលសំណើបណ្តឹងឧទ្ធរណ៍ដែលមានសុពលភាព បានកែសម្រួលរួចដែលឆ្លើយតបនឹងលក្ខខណ្ឌនៃផ្នែកនេះ

(7) នៅពេលផ្នែកផ្លាស់ប្តូរទទួលបានសំណើបណ្តឹងឧទ្ធរណ៍ដែលជំទាស់នឹងសិទ្ធិទទួលបានរបស់ ភាគីបណ្តឹងឧទ្ធរណ៍ ក្នុងគម្រោងសុខភាពវ៉ាស៊ីនតោនអេបផល, ផ្នែកកផ្លាស់ប្តូរ នឹងផ្ទេរបណ្តឹង ឧទ្ធរណ៍ទៅអាជ្ញាធរថែទាំសុខភាព តាមរយៈការបញ្ជូនព័ត៌មានបែបអេឡិចត្រូនិចប្រកបដោយសុវត្ថិភាពទៅក្នុងកម្មវិធី Healthplanfinder របស់ភាគីបណ្តឹងឧទ្ធរណ៍។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155. 520

5. ការបដិសេធបណ្តឹងឧទ្ធរណ៍

(1) មន្ត្រីអធិបតី ត្រូវតែបដិសេធបណ្តឹងឧទ្ធរណ៍ ប្រសិនបើ:

(ក) បណ្តឹងឧទ្ធរណ៍ មិនត្រូវបានស្នើ សម្រាប់មូលហេតុមួយក្នុងចំណោមមូលហេតុដែលមាន ក្នុងវិធាននីតិវិធី មាត្រា 3។

(ខ) ភាគីបណ្តឹងឧទ្ធរណ៍ មិនបានស្នើសុំបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល 90 ថ្ងៃ នៃកាលបរិច្ឆេទនៃការជូនដំណឹងអំពីសិទ្ធិទទួលបាន ដែលត្រូវបានប្តឹងឧទ្ធរណ៍។

(គ) ភាគីបណ្តឹងឧទ្ធរណ៍ មិនបង្ហាញខ្លួនតាមពេលដែលបានកំណត់សវនាការមុនពេលកាត់ក្តី ឬសវនាការ, ដោយមិនមានមូលហេតុត្រឹមត្រូវ។

(ឃ) ភាគីបណ្តឹងឧទ្ធរណ៍ ដកសំណើបណ្តឹងឧទ្ធរណ៍ អនុលោមតាមវិធាននីតិវិធី មាត្រា 17(1).

(ង) ភាគីបណ្តឹងឧទ្ធរណ៍ បានទទួលមរណភាព មុនពេលបណ្តឹងឧទ្ធរណ៍បញ្ចប់។

(2) ផ្នែកផ្លាស់ប្តូរ ត្រូវតែផ្ញើការជូនដំណឹងទាន់ពេលវេលា ទៅកាន់ភាគីបណ្តឹងឧទ្ធរណ៍ ដែលមានរៀបរាប់ពី:

(ក) មូលហេតុសម្រាប់ការបដិសេធបណ្តឹង។

(ខ) របៀបដែលការបដិសេធបណ្តឹង ប៉ះពាល់ដល់សិទ្ធិទទួលបានរបស់ភាគីបណ្តឹងឧទ្ធរណ៍សម្រាប់ ការបង់ប្រាក់ជាមុននៃចំនួនទឹកប្រាក់ឥណទានពន្ធបុព្វលាភ និងចំនួននៃការកាត់បន្ថយការចំណាយរួម។

(គ) របៀបដែលភាគីបណ្តឹងឧទ្ធរណ៍អាច, ក្នុងរយៈពេល 30 ថ្ងៃ នៃកាលបរិច្ឆេទ ការជូនដំណឹងនៃការបដិសេធបណ្តឹង, ដាក់សំណើជាលាយលក្ខណ៍អក្សរ បង្ហាញមូលហេតុត្រឹមត្រូវហេតុអ្វីការបដិសេធបណ្តឹងគួរតែចាត់ទុកជាមោឃៈ។

(ឃ) របៀបកែសម្រួលបណ្តឹងឧទ្ធរណ៍ និងដាក់ពាក្យបណ្តឹងម្តងទៀត។

(3) ច្រានចោលការបដិសេធបណ្តឹង: មន្ត្រីអធិបតី ត្រូវតែច្រានចោលការបដិសេធបណ្តឹង ប្រសិនបើភាគីបណ្តឹងឧទ្ធរណ៍ធ្វើសំណើជាលាយលក្ខណ៍អក្សរ មូលហេតុត្រឹមត្រូវ ច្រានចោលការបដិសេធបណ្តឹង និង អនុញ្ញាតបណ្តឹងឧទ្ធរណបន្ត។

(ក) សំណើ ត្រូវតែមានមូលហេតុត្រឹមត្រូវសម្រាប់ការមិនបដិសេធបណ្តឹងឧទ្ធរណ៍។

(ខ) ភាគីបណ្តឹងឧទ្ធរណ៍ ត្រូវតែធ្វើសំណើមួយ ច្រានចោលការបដិសេធបណ្តឹងក្នុងរយៈពេល 30 ថ្ងៃ នៃកាលបរិច្ឆេទនៃការជូនដំណឹងអំពីការបដិសេធបណ្តឹង។

(គ) ភាគីបណ្តឹងឧទ្ធរណ៍អាចស្នើ, ជាលាយលក្ខណ៍អក្សរ, សវនាការទាក់ទងនឹងសំណើ ច្រានចោលការបដិសេធបណ្តឹង។

(ឃ) ផ្នែកផ្លាស់ប្តូរ ត្រូវតែផ្តល់ឲ្យភាគីបណ្តឹងឧទ្ធរណ៍ការជូនដំណឹងជាលាយលក្ខណ៍អក្សរនៃ ការបដិសេធនៃសំណើច្រានចោលការបដិសេធបណ្តឹង, ប្រសិនបើវាត្រូវបានបដិសេធ។

(ង) ប្រសិនបើមន្ត្រីអធិបតី ច្រានចោលការបដិសេធបណ្តឹង, ផ្នែកផ្លាស់ប្តូរ ត្រូវតែ ផ្ញើជូនភាគីបណ្តឹងឧទ្ធរណ៍នូវព័ត៌មានក្នុងវិធានទីតិវិធី មាត្រា 4(4)។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155. 530

**6.** ការប្តឹងឧទ្ធរណ៍ឆាប់រហ័ស

(1) ភាគីបណ្តឹងឧទ្ធរណ៍ អាចស្នើការប្តឹងឧទ្ធរណ៍ឆាប់រហ័ស នៅពេលភាគីបណ្តឹងឧទ្ធរណ៍ អាចបង្ហាញ ពីតម្រូវការបន្ទាន់សម្រាប់សេវាសុខភាពពីព្រោះដំណើរការបណ្តឹងឧទ្ធរណ៍ធម្មតា អាចបង្ករហានិភ័យដល់

(ក) ជីវិត ឬ សុខភាពរបស់ភាគីបណ្តឹងឧទ្ធរណ៍; ឬ

(ខ) សមត្ថភាពក្នុងការទទួលបាន, រក្សា, ឬ មានកម្លាំងអតិបរមាឡើងវិញ។

(2) ការប្តឹងឧទ្ធរណ៍ឆាប់រហ័ស ត្រូវតែស្នើសុំក្នុងលក្ខណៈដូចគ្នានឹងបណ្តឹងឧទ្ធរណ៍ធម្មតា ដូចមានចែងក្នុងវិធានទីតិវិធី មាត្រា 4។

(3) នៅពេលដែលការប្តឹងឧទ្ធរណ៍ឆាប់រហ័ស ត្រូវបានស្នើសុំ, ភាគីបណ្តឹងឧទ្ធរណ៍ដាក់ជូន

(ក) ភស្តុតាងនៃមូលហេតុសម្រាប់ការប្តឹងឧទ្ធរណ៍ឆាប់រហ័ស; និង

(ខ) ភស្តុតាងនៃរបៀបការកំណត់សិទ្ធិទទួលបានគឺមិន។

(4) ប្រសិនបើមន្ត្រីអធិបតី យល់ព្រមលើសំណើ សម្រាប់ការប្ដឹងឧទ្ធរណ៍ឆាប់រហ័ស, ផ្នែកផ្លាស់ប្ដូរត្រូវតែចេញសាលក្រម មិនលើសពី 14ថ្ងៃ បន្ទាប់ពីផ្នែកផ្លាស់ប្ដូរទទួលបានសំណើ សម្រាប់ ការប្ដឹងឧទ្ធរណ៍ឆាប់រហ័ស។

(5) ប្រសិនបើមន្ត្រីអធិបតី បដិសេធសំណើ, ផ្នែកផ្លាស់ប្ដូរ ត្រូវតែ:

(ក) ដោះស្រាយសំណើបណ្ដឹងឧទ្ធរណ៍ក្រោមស្តង់ដារដំណើរបណ្ដឹងឧទ្ធរណ៍ និងចេញសាលក្រម ក្នុងរយៈពេល 90 ថ្ងៃ ចាប់ពីថ្ងៃទទួលបានសំណើ; និង

(ខ) ជម្រាបភាគីបណ្ដឹងឧទ្ធរណ តាមការគួរ និង មិនពន្យារពេល, ទាំងតាមការជូនដំណឹងបែប អេឡិចត្រូនិច ឬ ផ្ទាល់មាត់, ប្រសិនបើអាច, នៃការបដិសេធ និង, ប្រសិនបើការ ជូនដំណឹងផ្ទាល់មាត់, ត្រូវតាមដានភាគីបណ្ដឹងឧទ្ធរណ៍ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ការជូនដំណឹងជាលាយលក្ខណ៍អក្សរនៃការបដិសេធត្រូវតែរួមបញ្ចូល –

(i) មូលហេតុសម្រាប់ការបដិសេធ;

(ii) ការពន្យល់អំពីសំណើបណ្ដឹងឧទ្ធរណ៍ នឹងផ្ទេរទៅកាន់ស្តង់ដារដំណើរការ 90 ថ្ងៃ; និង

(iii) ការពន្យល់អំពីសិទ្ធិរបស់ភាគីបណ្ដឹងឧទ្ធរណ៍ក្រោមស្តង់ដារដំណើរការ 90 ថ្ងៃ,រួមមានពត៌មានក្នុងវិធានទីតិវិធី មាត្រា 4(4)។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155. 540

7. ដំណោះស្រាយក្រៅផ្លូវការ

(1) ផ្នែកផ្លាស់ប្ដូរបណ្ដឹងឧទ្ធរណ៍តាមរយៈដំណើរការដំណោះស្រាយក្រៅផ្លូវការ ដែលរួមមានដូច ខាងក្រោម:

(ក) សំណើបណ្ដឹងឧទ្ធរណ, ផ្នែកផ្លាស់ប្ដូរ នឹងពិនិត្យកំណត់ហេតុសិទ្ធិទទួលបាន និងរាល់ឯកសារ ភាគីបណ្ដឹងឧទ្ធរណ៍ដាក់ជូន, ដើម្បីកំណត់ថាតើសំណើរបស់ភាគីបណ្ដឹងឧទ្ធរណ៍អាចអនុញ្ញាត, ដោយមិនមាន ធ្វើទីតិវិធីសវនាការ។ ភាគីបណ្ដឹងឧទ្ធរណ៍ ឬ តំណាងភាគី បណ្ដឹងឧទ្ធរណ៍ ក៏អាចស្នើផ្នែកផ្លាស់ប្ដូរនូវដំណើរការដំណោះស្រាយក្រៅផ្លូវការ។

(2) ប្រសិនបើផ្នែកផ្លាស់ប្តូរនិងភាគីបណ្តឹងឧទ្ធរណ៍ យល់ព្រមដោះស្រាយបណ្តឹងឧទ្ធរណ៍, កិច្ចព្រមព្រៀង នៃដំណោះស្រាយក្រៅផ្លូវកា គឺចុងក្រោយ និងមិនអាចចាត់ទុកជាមោឃៈ , និងភាគីបណ្តឹងឧទ្ធរណ៍ ត្រូវតែជូនដំណឹងដល់ផ្នែកផ្លាស់ប្តូរ, ជាលាយលក្ខណ៍អក្សរ ឬដោយទូរស័ព្ទ, ថាខ្លួនដកបណ្តឹងឧទ្ធរណ៍។

(3) ភាគីបណ្តឹងឧទ្ធរណ៍ មានសិទ្ធិទទួលបានសវនាការមុនពេលកាត់ក្តី និង/ឬ សវនាការ ប្រសិនបើមិនមានដំណោះស្រាយក្រៅផ្លូវការ។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155. 535

8. សវនាការមុនពេលកាត់ក្តី

(1) មន្ត្រីអធិបតី នឹងបើកសវនាការមុនពេលកាត់ក្តីមិនតិចជាង 7 ថ្ងៃ មុនសវនាការ។

(2) នៅសវនាការមុនពេលកាត់ក, ផ្នែកផ្លាស់ប្តូរ និងភាគីបណ្តឹងឧទ្ធរណ៍, ឬតំណាងរបស់ភាគីបណ្តឹងឧទ្ធរណ៍, នឹងពិចារណា:

(ក) បញ្ហា នឹងត្រូវលើកឡើងនៅសវនាការ, រួមទាំងបញ្ហាច្បាប់;

(ខ) សាក្សីដែលនឹងផ្តល់ភស្តុតាងនៅសវនាការ, និងរាល់ការកំណត់ចំនួននៃសាក្សី ឬ អ្វីដែលគេនឹងផ្តល់ភស្តុតាង;

(គ) រាល់ឯកសារត្រូវតែដាក់ជូនសវនាការ;

(ឃ) ដំណោះស្រាយក្រៅផ្លូវការនៃបណ្តឹងឧទ្ធរណ៍ ដែលអាចមាន; និង

(ង) រាល់កិច្ចការផ្សេងទៀត ទាក់ទងនឹងប្រសិទ្ធភាពការប្រព្រឹត្តទៅនៃសវនាការ។

(3) សវនាការមុនពេលកាត់ក្តី នឹងត្រូវប្រព្រឹត្តទៅដោយមន្ត្រីអធិបតីម្នាក, តាមទូរស័ព្ទ ឬ វិធីផ្សេងទៀត តាមការព្រមព្រៀង ដោយផ្នែកផ្លាស់ប្តូរ និងភាគីបណ្តឹងឧទ្ធរណ៍, និងថតទុកជាបែបអេឡិចត្រូនិច។

(4) មន្ត្រីអធិបតី នឹងបញ្ជូនសាលក្រមសវនាការមុនពេលកាត់ក្តី ដែលកំណត់សកម្មភាពសវនាការមុនពេលកាត់ក្តី, រួមទាំងសាលក្រមដោយមន្ត្រីអធិបតី និងកិច្ចព្រមព្រៀងរវាងផ្នែកផ្លាស់ប្តូរ និងភាគីបណ្តឹងឧទ្ធរណ៍។

(5) ប្រសិនបើភាគីបណ្តឹងឧទ្ធរណ៍ ត្រូវបានផ្តល់ការជូនដំណឹង និង/ឬ ការយល់ព្រម, និងមន្ត្រីអធិបតី យល់ឃើញថាជាការត្រឹមត្រូវ, សាលក្រមចុងក្រោយ អាចធ្វើចុងបញ្ចប់នៃសវនាការមុនពេលកាត់ក្តី។

មិនមានផ្នែកណាក្នុងសាលក្រមនេះ គួរតែបកស្រាយដើម្បីកំណត់សិទ្ធិរបស់ភាគីបណ្ដឹងឧទ្ធរណ៍ សម្រាប់ទទួលការជូនដំណឹង, ការបន, ឬសវនាការ។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155. 535

**9.** សេចក្ដីជូនដំណឹងអំពីសវនាការ

(1) នៅពេលផ្នែកផ្លាស់ប្ដូរ រៀបចំកាលវិភាគសវនាការ, វាត្រូវតែផ្ញើការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ភាគីបណ្ដឹងឧទ្ធរណ៍ មិនតិចជាង 15 ថ្ងៃមុនកាលបរិច្ឆេទនៃសវនាការ។ ការជូនដំណឹងត្រូវតែមាន កាលបរិច្ឆេទ, ពេលវេលា, និងរបៀបនៃការប្រព្រឹត្តទៅនៃសវនាការ។ សម្រាប់ការហៅទូរស័ព្ទជាក្រុម, ការជូនដំណឹង ត្រូវតែមានលេខទូរស័ព្ទផ្ទាល់ខ្លួន និងរាល់ កូដភ្ជាប់ចូល ឬលេខសម្គាល់ផ្ទាល់ខ្លួន (PIN) តម្រូវឲ្យមានដើម្បីចូលរួមក្នុងសវនាការ។

(2) ការជូនដំណឹងនៃសវនាការ ត្រូវតែមានចែងថា ប្រសិនបើភាគីបណ្ដឹងឧទ្ធរណ៍មិនមានវត្តមាន ឬមិនបានចូលរួមក្នុងសវនាការ បណ្ដឹងឧទ្ធរណ៍ នឹងត្រូវបានបដិសេធ ដូចមានចែងក្នុងវិធានទីតិវិធី មាត្រា 5។

(3) ការជូនដំណឹងនៃសវនាការ អនុលោមតាមច្បាប់សហព័ន្ធ ត្រូវតែមានរៀបរាប់ថា ប្រសិនបើភាគី បណ្ដឹងឧទ្ធរណ៍ ឬ សាក្សីត្រូវការសេវាជំនួយសម្រាប់ភាពងាយស្រួល ឬអ្នកបកប្រែ, សេវាទាំងនេះនឹងត្រូវផ្ដល់ជូនដោយមិនគិតថ្លៃចំពោះភាគីបណ្ដឹងឧទ្ធរណ៍ ឬសាក្សី។ ការជូនដំណឹងត្រូវតែរួមមានទម្រង់សម្រាប់ភាគីដែលបង្ហាញថាត្រូវការសេវាជំនួយសម្រាប់ភាពងាយស្រួល ឬអ្នកបកប្រែក្នុងវិធានទីតិវិធីមាត្រា 16។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155.205, 155.535

**10.** សវនាការ

(1) សវនាការ នឹងត្រូវប្រព្រឹត្តទៅដោយមន្ត្រីអធិបតដោយមន្ត្រីអធិបតីម្នាក់, តាមទូរស័ព្ទ។ សវនាការអាចនឹងត្រូវប្រព្រឹត្តទៅដោយផ្ទាល់ ឬដោយវិធីដែលបានឯកភាពផ្សេងទៀតរវាងផ្នែកផ្លាស់ប្ដូរ និងភាគីបណ្ដឹងឧទ្ធរណ៍។ សវនាការ នឹងត្រូវថតទុកបែបអេឡិចត្រូនិចជាមុន។

(2) រាល់សវនាការ នឹងត្រូវប្រព្រឹត្តទៅដោយមន្ត្រីអធិបតីម្នាក់ ដែលមិនមានជាប់ពាក់ព័ន្ធដោយផ្ទាល់ ក្នុងការក ំណត់សិទ្ធិទទួលបានដែលត្រូវបានប្ដឹង។

(3) នៅសវនាការ, ភាគីបណ្ដឹងឧទ្ធរណ៍ អាច

(ក) បង្ហាញភស្ដុតាងពាក់ព័ន្ធនៃសាក្សីមួយ ឬច្រើន។

(ខ) បង្ហាញឯកសារ និងភស្ដុតាងពាក់ព័ន្ធផ្សេងទៀត ដែលបង្ហាញថាការកំណត់របស់ផ្នែកផ្លាស់ប្ដូរមិនត្រឹមត្រូវ ឬ មិនបានពិចារណាគ្រប់ជ្រុងជ្រោយ។

(គ) ប្រឈមមុខ និងសាកសួរសាក្សីខុសៗគ្នា, និងបដិសេធភស្ដុតាង។

(ឃ) បង្ហាញជំហររបស់ខ្លួន ដោយគ្មានការជ្រៀតជ្រែក។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155.535

## 11. បទដ្ឋាននៃការពិនិត្យឡើងវិញ

មន្ត្រីអធិបតី ត្រូវតែពិនិត្យកំណត់ហេតុបណ្ដឹងឡើងវិញ; រាល់ភស្ដុតាងត្រូវតែពិចារណាដោយមិនកែប្រែសេចក្ដីសម្រេចក្នុងការកំណត់សិទ្ធិទទួលបានដើម។

អាជ្ញាធរ : មាត្រា 45 CFR ផ្នែក 155.535

## 12. សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍

(1) មន្ត្រីអធិបតី ត្រូវតែចេញសាលក្រមជាលាយលក្ខណ៍អក្សរទៅកាន់ភាគីបណ្ដឹងឧទ្ធរណ៍ក្នុងរយៈពេល 90 ថ្ងៃ នៃកាលបរិច្ឆេទ ផ្នែកផ្លាស់ប្ដូរ ទទួលបានសំណើបណ្ដឹងឧទ្ធរណ៍, លើកលែងក្នុងករណីការប្ដឹងឧទ្ធរណ៍ឆាប់រហ័សក្រោមវិធានទីតិវិធីមាត្រា 6។

(2) សាលក្រម ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ, ផ្អែកលើតែភស្ដុតាងប៉ុណ្ណោះ ក្នុងកំណត់ហេតុ, និងរួមមាន:

(ក) សាលក្រម, រួមទាំងការពណ៌នាជាភាសាសាមញ្ញនៃឥទ្ធិពលលើសិទ្ធិទទួលបានរបស់ភាគីបណ្ដឹងឧទ្ធរណ៍;

(ខ) សង្ខេបនៃរឿងរ៉ាវពាក់ព័ន្ធ;

(គ) សេចក្ដីថ្លែងការណ៍នៃមូលដ្ឋានច្បាប់, រួមទាំងបទប្បញ្ញត្តិដែលគាំទ្រសាលក្រម;

(ឃ) កាលបរិច្ឆេទនៃសាលក្រមមានប្រសិទ្ធភាព;

(ង) ការពន្យល់នៃសិទ្ធិភាគីបណ្ដឹងឧទ្ធរណ៍ក្នុងការប្ដឹងសាលក្រមផ្នែកផ្លាស់ប្ដូរទៅកាន់ក្រសួងសេវាសុខភាព និងប្រជាជនអាមេរិច។

អាជ្ញាធរៈ មាត្រា 45 CFR ផ្នែក 155.545

**13.** បណ្តឹងឧទ្ធរណ៍នៃសេចក្តីសម្រេចផ្លាស់ប្តូរទៅ **HHS**

(1) ជាមួយនឹងការលើកលែងនៃបណ្តឹងឧទ្ធរណ៍និយោជក, ប្រសិនបើភាគីបណ្តឹងឧទ្ធរណ៍ យល់ព្រម នឹងសាលក្រមនៃផ្នែកផ្លាស់ប្តូរ, គេអាចធ្វើបណ្តឹងឧទ្ធរណ៍ ទៅកាន់ក្រសួងសេវាសុខាភិបាល និងសង្គមអាមេរិច (HHS) ក្នុងរយៈពេល 30 ថ្ងៃ នៃកាលបរិច្ឆេទជូនដំណឹងនៃសាលក្រម។

(2) ផ្នែកផ្លាស់ប្តូរ អាចផ្តល់ច្បាប់ចម្លងនៃទម្រង់ត្រឹមត្រូវ ទៅកាន់ភាគីបណ្តឹងឧទ្ធរណតាមសំណើ, ឬ ភាគីបណ្តឹងឧទ្ធរណ៍ អាចចូលទៅកាន់គេហទំព័រ https://www.healthcare.gov/marketplace-appeals/appeal-form-instructions សម្រាប់ច្បាប់ចម្លងនៃទម្រង់។ បន្ទាប់ពីបំពេញទម្រង់, ភាគីបណ្តឹងឧទ្ធរណ៍ ត្រូវតែទម្រង់សំបុត្រទៅកាន់៖

Health Insurance Marketplace
Attn: Appeals
465 Industrial Blvd
London, KY 40750-0061

ឬ ទូរសារសំណើបណ្តឹងឧទ្ធរណ៍ប្រកបដោយសុវត្ថិភាពទៅកាន់លេខ៖ 1-877-369-0130។

(3) ផ្នែកផ្លាស់ប្តូរ ត្រូវតែផ្ទេរសំណើបណ្តឹងឧទ្ធរណ៍ដើម និង កំណត់ហេតុបណ្តឹងរបស់អ្នកដាក់ពាក្យទៅកាន់ HHS តាមរយៈទូរសារប្រកបដោយសុវត្ថិភាពតាមបែបអេឡិចត្រូនិច។

អាជ្ញាធរៈ មាត្រា 45 CFR ផ្នែក 155.505 និង 155.545

**14.** ការផ្លាស់ប្តូរកាលបរិច្ឆេទនៃសវនាការមុនពេលកាត់ក្តី ឬ សវនាការ

(1) ភាគីបណ្តឹងឧទ្ធរណ៍ អាចស្នើឲ្យផ្នែកផ្លាស់ប្តូរ ផ្លាស់ប្តូរកាលបរិច្ឆេទសវនាការមុនពេលកាត់ក្តី ឬសវនាការ។

(2) សំណើផ្លាស់ប្តូរកាលបរិច្ឆេទត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ និងមានបញ្ជាក់មូលហេតុត្រឹមត្រូវក្នុងការផ្លាស់ប្តូរកាលបរិច្ឆេទសវនាការមុនពេលកាត់ក្តី ឬសវនាការ។ មន្រ្តីអធិបតី នឹងពិចារណាសំណើជាលាយលក្ខណ៍អក្សរ និង ចេញសាលក្រមជាលាយលក្ខណ៍អក្សរតាមការគួរ មិនថាជាការអនុញ្ញាត ឬ បដិសេធសំណើ។

(3) សំណើ ផ្លាស់ប្តូរកាលបរិច្ឆេទសវនាការមុនពេលកាត់ក្តី ឬសវនាការ នឹងមិនអនុញ្ញាតទេ ប្រសិនបើវានឹងបណ្តាលឲ្យសាលក្រមចុងក្រោយ ក្នុងបណ្តឹងឧទ្ធរណ៍ត្រូវធ្វើ ក្នុងរយៈពេល 90 ថ្ងៃ បន្ទាប់ពីផ្នែកផ្លាស់ប្តូរ ទទួលបានបណ្តឹងឧទ្ធរណ៍។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155.505 និង 155.535

**15.** ការតែងតាំងអ្នកតំណាងជំនួសភាគីប្តឹងឧទ្ធរណ៍

(1) ភាគីបណ្តឹងឧទ្ធរណ៍ អាចតែងតាំងបុគ្គលម្នាក់, ដូចជាមេធាវី ឬសមាជិកគ្រួសារ, ឬ អង្គការ, ដើម្បីតំណាងជំនួស អំឡុងពេលបណ្តឹងឧទ្ធរណ៍, រួមមានការស្នើបណ្តឹងឧទ្ធរណ៍ក្រោមវិធានទីតិវិធី មាត្រា 4។

(2) ភាគីបណ្តឹងឧទ្ធរណ៍ ត្រូវតែតែងតាំងអ្នកតំណាងជំនួសជាលាយលក្ខណ៍អក្សរ, រួមមានដូចខាងក្រោម:

(ក) លើទម្រង់បណ្តឹងឧទ្ធរណ៍ ផ្តល់ជូនដោយផ្នែកផ្លាស់ប្តូរ និងចុះហត្ថលេខាដោយ ភាគីបណ្តឹងឧទ្ធរណ៍;

(ខ) ក្នុងឯកសារជាលាយលក្ខណ៍អក្សរផ្សេងទៀត ចុះហត្ថលេខាដោយភាគីបណ្តឹងឧទ្ធរណ៍;

(គ) ដោយការតែងតាំងអ្នកតំណាងជំនួសតាមរយៈប្រព័ន្ធសិទ្ធិទទួលបាន Healthplanfinder;

(ឃ) ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរនៃការបង្ហាញខ្លួន តាមការផ្ញើសំបុត្រអាមេរិច ឬ អ៊ីមែល, ប្រសិនបើអ្នកតំណាងដែលបានអនុញ្ញាត គឺជាមេធាវីក្នុងវ៉ាស៊ីនតោន; ឬ

(ង) ដោយឯកសារច្បាប់, ការតែងតាំងអ្នកតំណាងជំនួសនៃភាគីបណ្តឹងឧទ្ធរណ៍, ដូចជាដីកាអាណាព្យាបាល ឬ អំណាចនៃមេធាវី។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155.227 និង155.505

**16.** ជំនួយសម្រាប់ភាពងាយស្រួល/អ្នកបកប្រែ

(1) ច្បាប់សហព័ន្ធ តម្រូវឲ្យផ្នែកផ្លាស់ប្តូររៀបចំដំណើរការដើម្បីអនុលោមតាមលក្ខខណ្ឌភាពងាយស្រួល ក្នុង § 155.205(c)។ នេះរួមមានការផ្តល់ព័ត៌មានជូនអ្នកដាក់ពាក្យ និងអ្នកចុះឈ្មោះ ជាភាសាសាមញ្ញ និងក្នុងលក្ខណៈដែលអាចទទួលយកបាន និងទាន់ពេលវេលាចំពោះ:

(ក) បុគ្គលមានពិការភាព, រួមទាំង គេហទំព័រងាយស្រួល និងការផ្តល់ជំនួយ និងសេវាដោយមិនគិតថ្លៃចំពោះបុគ្គល អនុលោមតាម ច្បាប់ជនពិការសហរដ្ឋអាមេរិច និងផ្នែក 504 នៃច្បាប់នីតិសម្បទា;

(ខ) បុគ្គលដែលភាសាអង់គ្លេសមានកម្រិត តាមរយៈការផ្ដល់សេវាភាសាដោយមិនគិតថ្លៃចំពោះ បុគ្គល, រួមមាន:

(i) ការបកប្រែផ្ទាល់មាត់, រួមមានសេវាអ្នកបកប្រែតាមទូរស័ព្ទ យ៉ាងតិច 150 ភាសា;

(ii) ការបកប្រែជាលាយលក្ខណ៍អក្សរ; និង

(iii) មានបង្ហាញពាក្យនៅខាងលើអំពី ភាសាដែលមិនមែនភាសាអង់គ្លេសចំនួន 15 ដែលមានសេវាភាសា; និង

(គ) ជម្រាបបុគ្គលអំពីការមាននៃសេវាទាំងនេះ និងរបៀបទទួលបានសេវានេះ។

(2) ទម្រង់បណ្ដឹងផ្នែកផ្លាស់ប្ដូរ ត្រូវតែមានកន្លែងសម្រាប់រាល់ភាគី បង្ហាញថាពួកគេត្រូវការ សេវាជំនួយសម្រាប់ភាពងាយស្រួល ឬអ្នកបកប្រែ ឬទេ។

(3) សាច់ញាតិ នៃរាល់ភាគី ឬ និយោជិក នៃផ្នែកផ្លាស់ប្ដូរ មិនអាចធ្វើអ្នកបកប្រែ ផ្នែកផ្លាស់ប្ដូរធ្វើនីតិវិធីបណ្ដឹង។

(4) មន្ត្រីអធិបតី ត្រូវតែកំណត់ ប្រសិនបើសេវាជំនួយសម្រាប់ភាពងាយស្រួល ឬអ្នកបកប្រែ គឺត្រឹមត្រូវ, មានប្រសិទ្ធភាព និង គាំទ្រដោយដោយស្មើភាពនីតិវិធីបណ្ដឹងសម្រាប់ភាគីបណ្ដឹងឧទ្ធរណ៍ ឬ សាក្សីដែលស្នើសុំសេវាជំនួយសម្រាប់ភាពងាយស្រួល ឬអ្នកបកប្រែ។ ប្រសិនបើក្នុងអំឡុងពេលធ្វើនីតិវិធីបណ្ដឹង មន្ត្រីអធិបតី កំណត់សេវាជំនួយសម្រាប់ភាពងាយស្រួល ឬអ្នកបកប្រែ គឺមិនផ្ដល់សេវាឲ្យដោយត្រឹមត្រូវ, មានប្រសិទ្ធភាព, និងស្មើភាព, មន្ត្រីអធិបតីត្រូវបដិសេដជំនួយសម្រាប់ភាពងាយស្រួល ឬជំនួយអ្នកបកប្រែផ្សេងទៀត និង រកសេវា ជំនួយសម្រាប់ភាពងាយស្រួល ឬជំនួយអ្នកបកប្រែដែលមានគុណភាពល្អជាង។

(5) មន្ត្រីអធិបតី ត្រូវតែអនុញ្ញាតនូវពេលវេលាគ្រប់គ្រាន់ អំឡុងពេលធ្វើនីតិវិធីបណ្ដឹង សម្រាប់ការបកប្រែរបស់អ្នកបកប្រែ ត្រូវបានធ្វើឡើង និងអាចយល់បាន។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155.205 និង 155.545

**17.** ការដកសំណើសុំសវនាការ

(1) អ្នកដែលបានស្នើបណ្ដឹងឧទ្ធរណ៍ អាចដកសំណើបណ្ដឹងឧទ្ធរណ៍ សម្រាប់រាល់មូលហេតុនៅគ្រប់ពេលវេលា អំឡុងពេលដំណើរការបណ្ដឹងឧទ្ធរណ៍។ សំណើសម្រាប់ការដកបណ្ដឹងត្រូវតែធ្វើ:

(ក) លើទម្រង់ផ្តល់ ដោយផ្នែកផ្លាស់ប្តូរ និងចុះហត្ថលេខាដោយភាគីបណ្តឹងឧទ្ធរណ៍, ឬ ការទំនាក់ទំនងជាលាយលក្ខណ៍អក្សរផ្សេងទៀត, ដូចជាទូរសារ, ឬ អ៊ីមែល ឬ

(ខ) ដោយទូរស័ព្ទ ប្រសិនបើផ្នែកផ្លាស់ប្តូរ ថតចម្លងពេញលេញនូវសេចក្តីថ្លែងរបស់ភាគីបណ្តឹង ឧទ្ធរណ៍ ក្រោមការពិន័យនៃការរំលោភបំពាន និងផ្នែកផ្លាស់ប្តូរ ផ្ញើទៅកាន់ភាគីបណ្តឹងឧទ្ធរណ៍ បញ្ជាក់ជាលាយលក្ខណ៍អក្សរ នៃការដកបណ្តឹង; ឬ

(គ) ដោយផ្ទាល់មាត់ទៅកាន់មន្ត្រីអធិបតី អំឡុងពេលធ្វើនីតិវិធីបណ្តឹង។

(2) ការស្នើបណ្តឹងឧទ្ធរណផ្នែកផ្លាស់ប្តូរអាចដកបណ្តឹង សំណើសវនាការដើម្បី ពិនិត្យមើលការបដិសេធនៃសិទ្ធិទទួលបានសម្រាប់គម្រោងសុខភាពវ៉ាស៊ីនតោនអេបផល។ សំណើ សម្រាប់ការដក ត្រូវតែធ្វើ:

(ក) លើទម្រង់ដែលបានផ្តល់ដោយផ្នែកផ្លាស់ប្តូរ និងចុះហត្ថលេខាដោយភាគីបណ្តឹងឧទ្ធរណ៍, ឬ ការទំនាក់ទំនងជាលាយលក្ខណ៍អក្សរផ្សេងទៀត, ដូចជា ទូរសារ, ឬ អ៊ីមែល;

(ខ) ដោយទូរស័ព្ទ ប្រសិនបើផ្នែកផ្លាស់ប្តូរ ថតចម្លងពេញលេញនូវសេចក្តីថ្លែងរបស់ភាគីបណ្តឹង ឧទ្ធរណ៍ ក្រោមការពិន័យនៃការរំលោភបំពាន និងផ្នែកផ្លាស់ប្តូរ ផ្ញើទៅកាន់ភាគីបណ្តឹងឧទ្ធរណ៍ បញ្ជាក់ជាលាយលក្ខណ៍អក្សរ នៃការដកបណ្តឹង; ឬ

(គ) ដោយផ្ទាល់មាត់ទៅកាន់មន្ត្រីអធិបតី អំឡុងពេលធ្វើនីតិវិធីបណ្តឹង។

នៅពេលផ្នែកផ្លាស់ប្តូរ ទទួលបានការដកបណ្តឹង, គេត្រូវផ្ទេររាល់ព័ត៌មានអំពីការដកបណ្តឹងឧទ្ធរណ៍ ទៅកាន់អាជ្ញាធរថែទាំសុខភាពដោយសុវត្ថិភាព។

(3) ទម្រង់ដែលបានផ្តល់សម្រាប់ការដកបណ្តឹងជាលាយលក្ខណ៍អក្សរ ត្រូវតែមានមូលហេតុសម្រាប់ការដកបណ្តឹង តម្រូវឲ្យចុះហត្ថលេខាទទួលស្គាល់ថាភាគីបណ្តឹងឧទ្ធរណ៍ គឺដឹងពីការដកសំណើបណ្តឹងឧទ្ធរណ៍ និងសិទ្ធិរបស់ពួកគេឡើងសវនាការ។

(4) ប្រសិនបើ ជនណាដកបណ្តឹងឧទ្ធរណ៍, មន្ត្រីអធិបតីត្រូវបញ្ជូនដីកាបដិសេធ បណ្តឹងឧទ្ធរណ៍ក្រោមវិធាននីតិវិធី មាត្រា 5។

អាជ្ញាធរ: មាត្រា 45 CFR ផ្នែក 155.505 និង155.530

**18.** ការដាក់ឯកសារទៅផ្នែកផ្លាស់ប្តូរ

(1) នៅពេលវិធានទីតិវិធីទាំងនេះ ឬដីកានៃមន្ត្រីអធិបតីទាមទារឲ្យភាគីបណ្តឹងឧទ្ធរណ៍ផ្តល់រាល់ឯកសារ ឬព័ត៌មានផ្សេងទៀតជូនទៅកាន់ផ្នែកផ្លាស់ប្តូរ, ភាគីបណ្តឹងឧទ្ធរណ៍ អាចផ្តល់ព័ត៌មានដោយ:

(ក) សំបុត្រ U.S., ទៅកាន់កម្មវិធីបណ្តឹងឧទ្ធរណ៍ WAHBE, P.O. Box 1757, Olympia, WA 98507-1757.

(ខ) អ៊ីមែល, ទៅកាន់ appeals@wahbexchange.org.

(គ) ដោយទូរសារ, ទៅកាន់ 360-841-7653។

(ឃ) ការដាក់ជូនដោយផ្ទាល់ដៃ, បញ្ជូនតាមសេវាដឹកជញ្ជូនពាណិជ្ជកម្ម, ទៅកាន់ផ្នែកផ្លាស់ប្តូរ, ទៅកាន់ 810 Jefferson St SE, Olympia, WA 98501-1417

(2) នៅពេលវិធានទីតិវិធីទាំងនេះ ឬ ដីកានៃមន្ត្រីអធិបតី ទាមទារឲ្យផ្នែកផ្លាស់ប្តូរ ទទួលបានឯកសារ, ឯកសារនោះ ត្រូវចាត់ទុកថាទទួលបានដោយផ្នែកផ្លាស់ប្តូរ នៅពេលវាមកដល់ការិយាល័យផ្នែកផ្លាស់ប្តូរ អំឡុងពេលម៉ោងធ្វើការធម្មតា។